-លោក សុខ សុរិយា

មាត្រា២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

* * *

## ២-សេចក្តីសំរេច

## សេចក្តីសំរេច លេខ ០៤ សសរ

## ស្តីពី

## ការប្រគល់ទីតាំង និងអាគារសាលាមធ្យមសិក្សាពាណិជ្ជកម្ម និង មជ្ឈមណ្ឌលកុមារបទី ៣

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

www.pheakdeylaw.com

**សម្រេច**

**ប្រការ ១** : ប្រគល់ដី និងអាគារវិទ្យាល័យភាសាបារាំង នៅភ្នំពេញ ( បច្ចុប្បន្ន សាលាមធ្យមសិក្សាពាណិជ្ជកម្ម នៃក្រសួងអប់រំ យុវជន និងកីឡា) អោយទៅរដ្ឋាភិបាលបារាំងគ្រប់គ្រង ដែលជាថ្នូរទៅនិងការផ្តល់វិភាគទានសំរាប់ការសាងសង់ឡើងវិញ នូវអាគារសាលាមធ្យមសិក្សាពាណិជ្ជកម្ម ។

**ប្រការ ២** : ប្រគល់ទីតាំងអាគារនិងដីមជ្ឈមណ្ឌលកូឡាបទីពា ស្ថិតនៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានផ្ទៃក្រឡាចំនួន ៦៤៥២.២៦ ម៉ែត្រក្រឡា អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា សំរាប់ការងារសាងសង់សាលាមធ្យមសិក្សា ពាណិជ្ជកម្ម ។

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និងកីឡា រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈≈≈

## សេចក្តីសំរេច លេខ ០៥ សសរ

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់ការនាំចូលតាមច្រកព្រំដែននូវសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគដែលនាំអោយប៉ះពាល់ដល់សុខភាពសាធារណៈ

-. បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com